ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
តាងនាមប្រជារាស្ត្រខ្មែរ

**តុលាការកំពូល**

**សភាផ្នែកព្រហ្មទណ្ឌ**

**សំណុំរឿងព្រហ្មទណ្ឌលេខ ៖ ៤៤**

**ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ១៩៩៨**

**សាលដីកាលេខ៖ ០៨**

**ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ ១៩៩៩**

បានឃើញសវនាការជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ១៧ ខែមីនា ឆ្នាំ ១៩៩៩ដោយមានសមាសភាពក្រុមប្រឹក្សាជំនុំជម្រះដូចទៅ៖

១ - ឯកឧត្តម... ជាប្រធាន

២ - លោក... ចៅក្រម

៣ - លោក... ចៅក្រម

៤ - លោក... ចៅក្រមរបាយការណ៍

៥ - លោក... ចៅក្រម

ក្រឡាបញ្ជី លោក...

តំណាងមហាអយ្យការ លោក...ព្រះរាជអាជ្ញា

ដើម្បីជំនុំជម្រះលើបណ្តឹងសារទុក្ខ ពីសាលដីកាព្រហ្មទណ្ឌលេខ២១ ចុះថ្ងៃទី១១ខែកញ្ញា របស់សាលាឧទ្ធរណ៍ និងសំណុំរឿងព្រហ្មទណ្ឌលេខ៤៤ ចុះថ្ងៃទី ១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៨ របស់តុលាការកំពូល។

ពីបទ៖ ប៉ុនប៉ងធ្វើមនុស្សឃាតដោយចេតនា ប្រព្រឹត្តកាលពីថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៨ នៅក្រុងភ្នំពេញ បទល្មើសដែលមានចែងតាមបញ្ញត្តិក្នុងមាត្រា ៣១ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ១៩៩២។

-ជនជាប់ចោទឈ្មោះ **ហស** "ជាចុងចម្លើយបណ្តឹងសាទុក្ខ" ភេទប្រុស អាយុ ២១ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើបេអឹម ទីលំនៅសព្វថ្ងៃ ផ្ទះលេខ ៤១៧ ផ្លូវលេខ ៣១០ សង្កាត់អូឡាំពិក ខណ្ឌចំការមន ក្រុងភ្នំពេញ ។ ឪពុកឈ្មោះ...ម្តាយឈ្មោះ...នៅលីវ ទោសពីមុនគ្មាន នៅក្រៅឃុំ។

-មេធាវី គ្មាន។

-ដើមបណ្តឹងរដ្ឋប្បវេណី និង ជាជនរងគ្រោះឈ្មោះ **ហហ** "ជាម្ចាស់បណ្តឹងសាទុក្ខ" ភេទប្រុស អាយុ៣៥ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់លេខ០៦ ក្រុងភ្នំពេញ របររកស៊ីលក់ដូរ មានទីលំនៅផ្ទះលេខ ១៣៨អឺ០ ផ្លូវលេខ២៨១ សង្កាត់ទួលស្វាយព្រៃទី២ ខណ្ឌចំការមន ក្រុងភ្នំពេញ។ ឪពុកឈ្មោះ... ម្តាយឈ្មោះ...ប្រពន្ធឈ្មោះ...មានកូន០២នាក់។ទោសពីមុនគ្មាននៅក្រៅឃុំ។

-មេធាវីលោក...ការពារក្តីឱ្យជនរងគ្រោះឈ្មោះ **ហហ**។

-តាមបណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩៨ របស់លោក **ហហ** ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល។

-តាមពាក្យបណ្តឹងចុះថ្ងៃទី២៧ ខែ មករា ឆ្នាំ១៩៩៨ ដើមបណ្តឹងរដ្ឋប្បវេណីលោក **ហហ** បានបញ្ជាក់ថា ខ្លួនសុំប្តឹងពីឈ្មោះ **ហស** ឈ្មោះ **ឡ** និងឈ្មោះ **ហង** ដែលបានប៉ុនប៉ងធ្វើឃាតខ្លួន ដោយហេតុថា កាលពីថ្ងៃទី ២៦ ខែមករា ឆ្នាំ ១៩៩៨ វេលាម៉ោង ៣ ០០គត់ ឈ្មោះ **ហស** បានដើរមកកន្លែងតូប

លក់ដូររបស់ខ្លួន ហើយនិយាយទៅកាន់ប្រពន្ធរបស់ខ្លួនថា ចែឯងល្មមប្រដៅកូនចែឯងផង ខ្លួនឮដូច្នេះក៏ងើបសួរឈ្មោះ **ហស** ថាមានរឿងស្អី ស្រាប់តែឈ្មោះ **ហស** ស្រែកថាអ្អែងក៏អញ្ចឹងដែរ អ្អែងកុំខ្លាំងបាញ់អ្អែងងាប់ ចោលកូនទាំងពីរម្តង ទន្ទឹមនឹងនោះដែរឈ្មោះ **ឡ** ត្រូវជាម្តាយមីងឈ្មោះ **ហស** ស្រែកថាអ្អែងបាញ់វាឱ្យងាប់ទៅនិយាយផុត ឈ្មោះ**ហស** ក៏ដកកាំភ្លើងខ្លី "មិនស្គាល់ម៉ាក" បាញ់សំដៅខ្លួន តែមិនចំទិសដៅដោយខ្លួនគេចផុតហើយឈ្មោះ **ឡ** ស្រែកថាបាញ់វាឱ្យងាប់ទៅ យ៉ាងច្រើនអស់លុយ ៥០០០ដុល្លា។ ពេលវាបាញ់រួចវាក៏គេចខ្លួនបាត់តែម្តង។ លុះក្រោយមកម៉ោងប្រហែល ៧ ០០ យប់ថ្ងៃដដែលឈ្មោះ **ហង** បានទូរស័ព្ទ មកគំរាមចង់សម្លាប់ខ្លួន និងជេរថាអាចុយម្រាយ អ្អែងចង់ងាប់អ្អែង...អញនឹងសម្លាប់អ្អែងចោលកូនទាំងពីរ។

-បានឃើញ ដីកាតម្កល់រឿងទុកមិនចាត់ការ លេខ ៦០៤ ចុះថ្ងៃទី ០៥ ខែឧសភា ឆ្នាំ១៩៩៨ របស់អយ្យការអមតុលាការក្រុងភ្នំពេញ ដែលសម្រេចតម្កល់រឿងព្រហ្មទណ្ឌលេខ ៨៥ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ទុកមិនចាត់ការ។

-បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ១៩៩៨ របស់លោក **ហហ** ដែលប្តឹងតវ៉ាដីកាតម្កល់រឿងទុកមិនចាត់ការលេខ ៦០៤ ចុះថ្ងៃទី ១២ ខែឧសភា ឆ្នាំ ១៩៩៨ របស់តំណាងអយ្យការអមតុលាការក្រុងភ្នំពេញ ដែលសម្រេចតម្កល់រឿងព្រហ្មទណ្ឌលេខ ៨៥ ចុះថ្ងៃទី ០៣ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ទុកមិនចាត់ការ។

-បានឃើញសេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមសាលាឧទ្ធរណ៍ថា៖ រឿងដែលមានផ្ទុះគ្រាប់កាំភ្លើង១គ្រាប់នេះ គឺផ្ទុះគ្រាប់ចុះទៅដីនិងគ្មានទិសដៅដូចឈ្មោះ ហស និងសាក្សី បានឆ្លើយថាបណ្តាលមកពីចលនាឃាត់

ហើយប៉ះទៅលើកែកាំភ្លើង។ ដូច្នេះអាចសួរថា តើមានចេតនាដែរឬទេ? រឿងមានសភាពជារឿងកំហែងគំរាម ប៉ុន្តែគ្មានបទល្មើស។

-បានឃើញសាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់សាលាឧទ្ធរណ៍ដែលបានសម្រេច៖

១-ទទួលពាក្យបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១២.០៥.១៩៩៨ របស់ឈ្មោះ **ហហ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់ដីកាសម្រេចតម្កល់រឿងទុកឥតចាត់ការលេខ ៦០៤ ចុះថ្ងៃទី ០៥ ខែ ឧសភា ឆ្នាំ១៩៩៨ របស់ព្រះរាជអាជ្ញាអមតុលាការក្រុងភ្នំពេញ ទុកជាបានការដដែល។

៣-សាលដីកានេះជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ បើកផ្លូវប្តឹងទាស់ និងសាទុក្ខតាមកំណត់ច្បាប់។

-បានឃើញបណ្តឹងសាទុក្ខលេខ៣៩ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ១៩៩៨ របស់លោក **ហហ** ដែលប្តឹងតវ៉ាពីសាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល។

-បានឃើញ សារណាចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៨ របស់លោក **ហហ** ជាម្ចាស់បណ្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានឃើញ សារណាឆ្លើយតប ចុះថ្ងៃទី ១៩ ខែមករា ឆ្នាំ១៩៩៨ របស់ **ហស** ជាចុងបណ្តឹងសាទុក្ខ ធ្វើឡើងក្នុងកំណត់ច្បាប់។

-បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

-បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ ក្រោយពីបានពិនិត្យលើសំណុំរឿងទាំងមូលមក មហាអយ្យការយល់ឃើញថា សាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ។ ហេតុនេះសូមក្រុមប្រឹក្សាជំនុំជម្រះ មេត្តាពិនិត្យនិងសម្រេច។

-បានស្តាប់អំណានសារណារបស់លោក **ហស** ជាចុងបណ្តឹងសាទុក្ខនៅពេលជំនុំជម្រះ។

-បានស្តាប់ចម្លើយអះអាងរបស់លោក **ហហ** ជាម្ចាស់បណ្តឹងសាទុក្ខនៅពេលជំនុំជម្រះថា៖ កាលដែលខ្ញុំសុំប្តឹងសាទុក្ខមកតុលាការកំពូល ព្រោះការសម្រេចសេចក្តីកន្លងមកនេះមានភាពអយុត្តិធម៌ណាស់ **ហស** មានបំណងបាញ់សម្លាប់ខ្ញុំយ៉ាងពិតប្រាកដ តែដោយសារម្តាយមីង **ហស** ទះដៃចេញម្ល៉េះពេលនោះ ខ្ញុំបាទបានស្លាប់បាត់ទៅហើយ ការដែលខ្ញុំបានរួចខ្លួនមកដល់ពេលនេះដោយសារថាពេលផ្ទុះអាវុធ អាជីវករ និងអ្នកទិញរត់ប្រសេចប្រសាច ជាហេតុធ្វើឱ្យ **ហស** ពុំមានលទ្ធភាពបាញ់ខ្ញុំបន្តទៀត។ ក្រោយពេលផ្ទុះអាវុធ ឈ្មោះ **ហស** បានគេចខ្លួនរហូតខ្ញុំបាទបានប្តឹងទៅទីស្នាក់ការផ្សារអូឡាំពិក តែឈ្មោះនេះគេចខ្លួន ខ្ញុំបាទក៏ប្តឹងទៅព្រះរាជអាជ្ញាពុំព្រមធ្វើការកោះហៅសាក្សី ដែលនៅជិតនោះមកធ្វើការបំភ្លឺទេ គឺហៅតែក្រុមគ្រួសារជនល្មើស មកសួរនាំតែប៉ុណ្ណោះ។ ហើយសូម្បីតែហៅខ្ញុំបាទទៅសួរចម្លើយក៏មានការគំរាមកំហែងដែរនេះដោយសារតែតុលាការកាន់ជើងជនល្មើស។

-បានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់លោក **សហ** ជាមេធាវីឱ្យលោក **ហហ** ជាម្ចាស់បណ្តឹងសាទុក្ខ នៅពេលជំនុំជម្រះថា៖ ព្រះរាជអាជ្ញាអមតុលាការ

ក្រុងភ្នំពេញ មិនបានអង្កេតរកបទល្មើស តាមព្រឹត្តហេតុដែលកើតឡើងនោះឡើយ ហើយថែមទាំងមិនបានធ្វើសេចក្ដីសន្និដ្ឋាន បញ្ជូនរឿងឱ្យស៊ើបសួរទៅថៅក្រមតាមមាត្រា៦០ នៃច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌឡើយ។

អំពើដែលឈ្មោះ **ហស** ប្រព្រឹត្តគឺជាអំពើប៉ុនប៉ងធ្វើមនុស្សឃាត ដែលមានលក្ខណៈពេញលេញកំណត់ដោយធាតុផ្សំបទល្មើស ដំណាក់កាលនៃការប្រព្រឹត្ត បានឆ្លុះបញ្ចាំងពីស្ថានភាពប្រព្រឹត្តស្ថានជំរុញឱ្យប្រព្រឹត្ត អំពើសកម្មភាពប្រព្រឹត្តនិងមានភស្តុតាងគ្រប់គ្រាន់ សំរាប់ជាមូលដ្ឋានបញ្ជាក់ថាអំពើនេះពិតជាអំពើព្រហ្មទណ្ឌ បទឧក្រិដ្ឋដែលត្រូវបានច្បាប់ចែង និងការពារតាមមាត្រា៣២ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ករណីនេះយោងតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍ ចុះថ្ងៃទី ០៧. ៨. ៩៨។

ខ្ញុំសូមឱ្យលោកមហាអយ្យការតុលាការកំពូល មេត្តាឯកភាពតាមសេចក្ដីសេចសន្និដ្ឋានរបស់ព្រះរាជអាជ្ញាសាលាឧទ្ធរណ៍។ សូមឱ្យតុលាការកំពូល ធ្វើការចោទប្រកាន់ជនល្មើសតាមច្បាប់ឱ្យសមនឹងអំពើប្រព្រឹត្ត កាលពីថ្ងៃទី ២៦. ០១.១៩៩៨។ សូមឱ្យឃុំខ្លួនជនល្មើស ដកហូតឧបករណ៍ប្រព្រឹត្តល្មើសនិងផ្ដន្ទាទោសជនល្មើស ពីបទអាជ្ញាគតិតាមបញ្ញត្តិច្បាប់ខាងលើ។

-បានស្ដាប់សេចក្ដីសន្និដ្ឋានបន្ថែម នាពេលសវនាការ របស់តំណាងមហាអយ្យការអមតុលាការកំពូលថា៖ តំណាងមហាអយ្យការ ពុំមានយោបល់អ្វីបន្ថែមទៀតទេ សូមរក្សាសេចក្ដីសន្និដ្ឋាននៅដដែល

-ក្រោយពីបានស្ដាប់ របាយការណ៍ចៅក្រមរបាយការណ៍

-ក្រោយពីបានស្ដាប់ សេចក្ដីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់ ចម្លើយរបស់ដើមបណ្តឹងរដ្ឋប្បវេណីសារណាតប របស់ជនជាប់ចោទ និង សេចក្តីសន្និដ្ឋានការពាររបស់មេធាវីដើមបណ្តឹងរដ្ឋប្បវេណី។

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

**តុលាការកំពូល**

-យល់ឃើញថា: បណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ១៩៩៨ របស់លោក **ហហ** ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជម្រះបានតាមមាត្រា១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំនុំជម្រះក្តី។

-យល់ឃើញថា៖ លទ្ធផលនៃការស៊ើបអង្កេត របស់អយ្យការអមតុលាការក្រុងភ្នំពេញពុំមានបង្ហាញភស្តុតាងគ្រប់គ្រាន់ ដូចការចោទប្រកាន់ របស់លោក **ហហ** ក្នុងសារណាចុះថ្ងៃទី ២៤.១២.៩៨ ដែលថាឈ្មោះ **ហស** បានបាញ់មកលើលោកចំនួន០១គ្រាប់ ហើយក្រោយពេលបាញ់ រកឱកាសបាញ់សំដៅសម្លាប់លោក ០១គ្រាប់ទៀតនោះឡើយ។

-យល់ឃើញថា៖ ជនជាប់ចោទ បានធ្វើសារណាតបជូនមកតុលាការកំពូល និងបានទទួលដីកាកោះរួចហើយ ប៉ុន្តែពុំបានចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជម្រះរឿងនេះ កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខ។

-យល់ឃើញថា: សាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ១១.៩.៩៨ របស់របស់សាលាឧទ្ធរណ៍ ដែលបានសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់និងគតិច្បាប់ហើយ។

## ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តីចំពោះមុខ ដើមបណ្តឹងរដ្ឋប្បវេណី កំបាំងមុខជនជាប់ចោទ ប៉ុន្តែចាត់ទុកជាចំពោះមុខៈ

១-ទទួលបណ្តឹងសាទុក្ខលេខ ៣៩ ចុះថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ១៩៩៨ របស់លោក **ហហ** ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងគតិច្បាប់។

២-តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ២០១ ចុះថ្ងៃទី ១១.៩.៩៨ របស់សាលាឧទ្ធរណ៍ទុកជាបានការពេញលេញទាំងមូល។

៣-សាលដីកានេះ ប្រកាសទាសវនាការជាសាធារណៈនៅថ្ងៃទី១៧ ខែមីនា ឆ្នាំ ១៩៩៨។